# កំណាព្យ

## រូបនៃស្នេហា

បទបន្ទោលកាក

រូបនៃស្នេហា   មានក្នុងចិន្តាជាទ្រព្យ
ជាភ័ព្វបុគ្គល   មង្គលក្នុងក្ដីមេត្តា។
រូបស្នេហ៍មានពិត   ពិនិត្រតាមចិត្តរតនា
ឃើញស្នេហ៍រចនា   រូបត្បាញក្នុងចិត្តមេត្រី។
រូបគុណសម្បត្តិ   គ្មានគុណវិបត្តិជាគ្នា
ព្រោះស្នេហ៍ខ្នុរខ្នារ   គ្រប់គ្រាបង្កើតរូបចិត្ត។
រូបល្អវិចិត្រ   ករុណាផ្ដិតក្នុងសួន
នៃស្នេហារួម   កាយចិត្តបង្រួមមួយមូល។
រូបនៃស្នេហា   តម្កល់រក្សាស្នេហ៍ឫទ្ធិ
គង់ចាំចិត្តគិត   គូពីអតីតវិសុទ្ធិ។
ជារូបស្រឡាញ់   គ្មានចិត្តាខ្នាញ់រកខុស
ឥតម៉ៃកំហុស   នាំសុខឱ្យមានរសាប់។